

ផលិតផលធានារ៉ាប់រងដែលការពារមនុស្សជាទីស្រលាញ់របស់អ្នកពីបន្ទុកហិរញ្ញវត្ថុដោយទូទាត់កម្ចីរបស់អ្នក ប្រសិនបើមានហេតុការណ៍អកុសលណាមួយកើតមានចំពោះអ្នក។

## ★ សារៈសំខាន់

- គ្រួសាររបស់អ្នកមិនចាំបាច់បារម្ភពីការទូទាត់កម្ចីនៅពេលគ្មានរូបអ្នក។
- ការការពារដែលមានតម្លៃទាប ដើម្បីធានាថាមនុស្សជាទីស្រលាញ់របស់អ្នកអាចរស់នៅដោយមិនជាប់បំណុល។
- ត្រូវគ្នាទៅនឹងទំហំកម្ចីរបស់អ្នក។

**100%** នៃចំនួនទឹកប្រាក់ធានារ៉ាប់រង ឬចំនួនទឹកប្រាក់ធានារ៉ាប់រងថយចុះ នឹងត្រូវបានទូទាត់ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ចំនួនទឹកប្រាក់ធានារ៉ាប់រងថេរ **$5,000** លើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) ដែលបណ្ដាលមកពីគ្រោះថ្នាក់

ជម្រើស
ទឹកប្រាក់ធានារ៉ាប់រងថេរ
ឬ ទឹកប្រាក់ធានារ៉ាប់រងថយចុះ

ជម្រើស
បង់បុព្វលាភតែមួយលើក ឬ
បង់បុព្វលាភជាប្រចាំមានកាលកំណត់

ខិត្តប័ណ្ណនេះផ្ដល់នូវព័ត៌មានបឋមអំពីផលិតផលប៉ុណ្ណោះ។ លោកអ្នកត្រូវអាន ខ និងលក្ខខណ្ឌនៃផលិតផលនេះ ដើម្បីជ្រាបពីព័ត៌មានលម្អិត ហើយស្វែងរកការប្រឹក្សាយោបល់ពីបុគ្គលិកលក់ផលិតផលធានារ៉ាប់រង ឬភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលរបស់យើងខ្ញុំ មុននឹងសម្រេចចិត្តទិញបណ្ណសន្យារ៉ាប់រងនេះ។



Fortune Life Insurance PLC fortunelifecambodia
www.fortunelife.com.kh +855 23 931 999 | 1800-202 202 ឥតគិតថ្លៃ
អគារ The Gateway ជាន់ទី26 មហាវិថីសហព័ន្ធរុស្ស៊ី (ផ្លូវ110) សង្កាត់ផ្សារដេប៉ូទី3 ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Fortune
LIFE INSURANCE

# ផលិតផលការពារកម្ចី

## ជាមួយ ហ្វ័រឈូន ឡាយហ្វ៍



# ដំណើរការរបស់ផលិតផល

លោកសម្បត្តិ មានអាយុ30ឆ្នាំ បានខ្ចីកម្ចីដែលមានទឹកប្រាក់ចំនួន **$5,000** ដោយមានរយៈពេលសង 3ឆ្នាំ ពីគ្រឹះស្ថានហិរញ្ញវត្ថុមួយ។ ស្របពេលជាមួយគ្នានេះដែរ គាត់ទិញ “ផលិតផលការពារកម្ចីជាមួយ ហ្វ៊ែរឈូន ឡាយហ្វ៍” ដែលមានទឹកប្រាក់ធានារ៉ាប់រងថេរ ដើម្បីធានាថា កម្ចីនេះនឹងមិនក្លាយជាបន្ទុកហិរញ្ញវត្ថុទៅលើគ្រួសាររបស់គាត់នៅពេលដែលគ្មានរូបគាត់។ លោកសម្បត្តិបានបង់បុព្វលាភតែមួយលើកចំនួន **$154.60** ដើម្បីទិញផលិតផលនេះ។






ប្រសិនបើមានហេតុការណ៍អកុសលណាមួយកើតឡើងចំពោះលោកសម្បត្តិ ក្នុងខែទី18 (1ឆ្នាំកន្លះ) បន្ទាប់ពីគាត់បានទិញបណ្ណសន្យារ៉ាប់រង ក្រុមហ៊ុន ហ្វ៊ែរឈូន ឡាយហ្វ៍ នឹងទូទាត់សមតុល្យកម្ចីទឹកប្រាក់ចំនួន **$2,897** ដែលនៅសល់ និងរាល់ចំនួនទឹកប្រាក់ធានារ៉ាប់រងដែលនៅសល់ចំនួន **$2,103** នឹងត្រូវប្រគល់ជូនក្រុមគ្រួសាររបស់លោកសម្បត្តិ (អ្នកទទួលផល)។

# ករណីមិនធានា

រាល់ការទាមទារសំណងចំពោះមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (TPD) របស់អ្នកត្រូវបានធានារ៉ាប់រងទាំងឡាយណាដែលកើតឡើងដោយផ្ទាល់ ឬប្រយោលដោយមូលហេតុខាងក្រោម នឹងមិនត្រូវបានធានាឡើយ៖

## 1. អត្ថប្រយោជន៍ក្នុងករណីមរណភាពឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ (បណ្តាលមកពីមូលហេតុទូទៅ)៖

ក. ការធ្វើអត្តឃាតឬប៉ុនប៉ងធ្វើអត្តឃាតទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតីឬមានវិបល្លាសក៏ដោយ ឬ

ខ. ឆ្លងមេរោគហ៊ីវ(HIV) ឬជំងឺអេដស៍(AIDS) ឬជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធនឹងមេរោគហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS) ឬ

គ. ការប្រើប្រាស់ខុសច្បាប់នូវថ្នាំណាកូទីគ (narcotics) ថ្នាំរំញោច (stimulants) ឬសារធាតុញៀនដទៃទៀត ឬ

ឃ. ទទួលទោសប្រហារជីវិត ឬចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬប្រឆាំងនឹងការចាប់ខ្លួនរបស់អាជ្ញាធរ ឬសកម្មភាពលួចចេញពីពន្ធនាគារ ឬ

ង. សកម្មភាពខុសច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផល ដែលរំលោភទៅនឹងបទបញ្ញត្តិនានា ដូចដែលបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ឬ

ច. ពិការភាព កើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទបន្តសុពលភាពឡើងវិញ ឬ

ឆ. សង្គ្រាម(ទោះមាន ឬមិនមានការប្រកាសជាមុន)សង្គ្រាមស៊ីវិល ឬជម្លោះប្រដាប់អាវុធផ្សេងៗ ឬ

ជ. ការបង្កគ្រោះថ្នាក់ដោយខ្លួនឯង របស់អ្នកត្រូវបានធានារ៉ាប់រង/ម្ចាស់បណ្ណសន្យារ៉ាប់រង ទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិបល្លាសក៏ដោយ ឬ

ឈ. ចូលរួមនៅក្នុងសកម្មភាពហោះហើរ លើកលែងតែជាអ្នកដំណើរនៃអាកាសចរណ៍ស៊ីវិលដែលមានកាលវិភាគហោះហើរ ឬ

ញ. បម្រើការងារក្នុងជួរយោធា ឬកងទ័ពជើងទឹកនៅក្នុងអំឡុងពេលដែលមានសង្គ្រាម (ទោះមាន ឬមិនមានការប្រកាសជាមុន) ឬនៅក្រោមបញ្ជានៃប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ។

## 2. អត្ថប្រយោជន៍បន្ថែមក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ (បណ្តាលមកពីគ្រោះថ្នាក់)៖

ប្រការ 1 ខាងលើឬបណ្តាល មកពីមូលហេតុណាមួយដូចខាងក្រោម៖

ក. ការស្នើសុំវះកាត់ ដែលសំដៅដល់ការវះកាត់តាមនីតិវិធីក្បួនវេជ្ជសាស្ត្រ រួមទាំងការវះកាត់កែសម្ផស្ស ដោយមិនចាំបាច់ឈរលើមូលដ្ឋានវេជ្ជសាស្ត្រឡើយ ដែលពាក់ព័ន្ធនឹងជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលស្ថិតក្រោមការការពារនៃបណ្ណសន្យារ៉ាប់រងនេះ ដែលបានធ្វើឡើងតាមសំណើរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ឬ

ខ. អ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ស្រាបៀរ (ដែលល្មើសនឹងបទប្បញ្ញត្តិច្បាប់ដែលមានចែងក្នុងច្បាប់កម្ពុជាជាធរមាន) ឬថ្នាំដែលមិនមានវេជ្ជបញ្ជាត្រឹមត្រូវ ឬ

គ. ការប៉ះពាល់ផ្នែករាងកាយ ឬផ្លូវចិត្ត ឬស្ថានភាពចុះខ្សោយ ឬភាពទ្រុឌទ្រោម ដែលត្រូវបានបញ្ជាក់ថាបានកើតឡើងមុនពេលកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រងនេះដោយមិនត្រូវបានប្រកាសឱ្យបានពេញលេញ និងត្រឹមត្រូវ ឬ

ឃ. ចូលរួមក្នុងសកម្មភាពគ្រោះថ្នាក់ រួមទាំងតែមិនកំណត់ចំពោះ ការជ្រមុជទឹក ការលោតខ្សែយោង ការលោតឆ័ត្រយោង ការឡើងភ្នំ ការប្រណាំងសេះ ឬការប្រណាំងផ្សេងទៀតដែលមានកង់រិល ឬ

ង. អាវុធនុយក្លេអ៊ែរ វិទ្យុសកម្ម ឬវិទ្យុសកម្មពីសារធាតុនុយក្លេអ៊ែរ ឬកាកសំណល់នុយក្លេអ៊ែរ ដែលកើតចេញពីចំហេះនៃសារធាតុនុយក្លេអ៊ែរ និងដំណើរការនៃការបែងចែក/ការលាយនុយក្លេអ៊ែរដើម្បីទ្រទ្រង់ខ្លួនឯង ឬ

ច. ចូលរួមក្នុងការវាយតប់ ការតស៊ូមតិ ឬឈរប្រឆាំងនឹងការចាប់ខ្លួនអាជ្ញាធរមានសមត្ថកិច្ច ឬ

ឆ. ផលវិបាកដែលទាក់ទងនឹងការមានផ្ទៃពោះ ការសម្រាលកូន។

